# មេរៀនទី ៣៩៖ ព្រះយកចិត្តទុកដាក់ចំពោះហាការ និងអ៊ីសម៉ាអែល

## លោកុប្បត្តិ ២១៖៨-២១

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/l9n2VqH-Jo8

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/sMPhi6fT4J8

**គោលបំណង៖ ព្រះតែងតែឮពីពួកយើង នៅពេលដែលយើងអធិស្ឋាន។**

**ខគម្ពីរចងចាំ៖ យ៉ូហាន ១៥៖៧** *"បើអ្នករាល់គ្នានៅជាប់នឹងខ្ញុំ ហើយពាក្យខ្ញុំនៅជាប់ក្នុងអ្នករាល់គ្នា នោះចូរសូមអ្វីតាមតែប្រាថ្នាចុះ សេចក្តីនោះនឹងបានសំរេចដល់អ្នករាល់គ្នាជាមិនខាន។"*

**ចំរៀង** ( *យូធូបលីង* )៖

១. ក្នុងពេលទ្រង់ https://youtu.be/uOmu3Qm5pr0
២. ទ្រង់ធ្វើឱ្យខ្ញុំសប្បាយ https://youtu.be/S6mflMXkLNc
៣. ខ្ញុំនឹងទុកចិត្តទ្រង់ https://youtu.be/WCZlwlstAzc

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត «បញ្ចុកនំ»

សម្ភារៈដែលត្រូវការ៖ នំ អំបិល ក្រូចឆ្មារ ម្ទេសម៉ត់ ចាន ក្រមា( សម្រាប់ចងភ្នែក )



១. គ្រូត្រូវយកនំទៅប្រឡាក់ជាមួយ អំបិល ក្រូចឆ្មារ ម្ទេសម៉ត់
២. ចែកកុមារជាពីរក្រុម ហើយជ្រើសរើសកុមារម្នាក់ពីក្រុមនីមួយៗ ហើយចងភ្នែកកុមារនោះ
៣. កុមារទាំងពីរដែលបានរុំភ្នែកហើយនោះ ត្រូវយកនំពីចានម្នាក់មួយ ហើយបញ្ចុកទៅកុមារដែលបានរុំភ្នែកម្នាក់ទៀតនោះ។



កុមារណាដែល អាចញុំនំបោះអស់មុននោះក្រុមរបស់គេនឹងទទួលបានមួយពិន្ទុ។
៤. បន្តលេងល្បែងនេះរហូតដល់កុមារបានលេងគ្រប់ៗគ្នា។ ក្រុមណាដែលមានពិន្ទុច្រើនជាងក្រុមនោះជាអ្នកឈ្នះ។
៥. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ដូចជាការដែលនំមានរសជាតិខុសៗគ្នា ដូចជាជីវិតនៃការរស់នៅរបស់យើងជួបប្រទះទៅនឹងបញ្ហាខុសៗគ្នា ដែលជួនកាលធ្វើឲ្យយើងសប្បាយចិត្ត កើតទុក្ខ មិនសប្បាយចិត្ត ឬខឹង។ ប៉ុន្តែគ្រប់កាលៈទេសៈទាំងអស់ នៅពេលដែលយើងអធិស្ឋានទៅព្រះ ព្រះនឹងឆ្លើយតបនឹងការអធិស្ឋានរបស់យើង។

### ៤. ការណែនាំមេរៀន

តើអ្នកធ្លាប់យំទេ? ហេតុអ្វីបានជាអ្នកយំ? តើអ្នកកធ្លាប់កើតទុក្ខទេ? តើអ្នកធ្លាប់ឈឺចាប់ទេ? តើអ្នកធ្លាប់ខឹងទេ? គឺមានរឿងជាច្រើននៅក្នុងជីវិតដែលធ្វើឲ្យអ្នកកើតទុក្ខ និងខឹង។ យើងនៅតែអាចពឹងផ្អែកលើព្រះនៅពេលយើងជួបប្រទះស្ថានភាពបែបនោះ ពីព្រោះទ្រង់តែងតែឮនៅពេលដែលយើងអធិស្ឋាន។ ថ្ងៃនេះយើងនឹងរៀនពីបុគ្គលពីនាក់ដែលបានអធិស្ឋានទៅកាន់ព្រះ ហើយព្រះបានឆ្លើយតបនៅពេលដែលពួកគេជួបប្រទះនឹងការលំបាក។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ថ្ងៃនេះរឿងនៅក្នុងព្រះគម្ពីររបស់យើងគឺនិយាយអំពី ពីរគ្រួសារដែលរស់នៅមិនចុះសម្រុងនឹងគ្នា។ សារ៉ា អាប្រាហាំ ហើយនឹងអ៊ីសាកគឺជាគ្រួសារតែមួយ។ សារ៉ា និងអ័ប្រាហាំគឺជាឪពុកម្តាយ ហើយអ៊ីសាកគឺជាកូនប្រុសរបស់ពួកគេ។ អ៊ីសាកគឺមានអាយុប្រហែល ៣ឆ្នាំនៅពេលដែលមានរឿងនេះកើតឡើង។

ឥឡូវនេះអ័ប្រាហាំមានគ្រួសារមួយទៀត។ ជាច្រើនឆ្នាំមុនពេលដែលអ៊ីសាកកើត សារ៉ាមានការព្រួយបារម្ភថា ព្រះមិនប្រទានកូនឲ្យអ័ប្រាហាំតាមរយៈផ្ទៃរបស់នាង ដូច្នេះនាងបានទៅប្រាប់ឲ្យអ័ប្រាហាំឲ្យចាប់ផ្តើមគ្រួសារថ្មីជាមួយអ្នកបម្រើរបស់នាងគឺហាការ។ ហើយអាប្រាហាំក៏បង្កើតបានកូនប្រុសម្នាក់ឈ្មោះ អ៊ីស-ម៉ាអែល ជាមួយនឹងហាការ ហើយនៅពេលដែលអ៊ីសាកកើត អ៊ីសម៉ាអែលគឺមានវ័យជំទង់ទៅហើយ ។

សារ៉ា និងហាការគឺមិនចូលចិត្តគ្នានោះទេ។ គឺមានការច្រណែនគ្នាជាច្រើនរវាងសារ៉ា និងហាការ។ នៅចុងបញ្ចប់សារ៉ាបានប្រាប់អ័ប្រាហាំឲ្យដេញហាការ និងកូនប្រុសរបស់នាងគឺអ៊ីសម៉ាអែល ឲ្យចាកចេញឲ្យឆ្ងាយ។ អ័ប្រាហាំមិនដឹងថាគាត់ត្រូវធ្វើបែបណានោះទេ ពីព្រោះគាត់ស្រលាញ់អ៊ីសម៉ាអែល ដែលជាកូនប្រុសគាត់។ ប៉ុន្តែគាត់ក៏ស្រលាញ់សារ៉ា និងកូនប្រុសរបស់គាត់គឺអ៊ីសាកដែរ។ គាត់មិនដឹងថាគាត់ត្រូវធ្វើយ៉ាងណាដើម្បីដោះស្រាយបញ្ហានេះ និងបញ្ឈប់ជម្លោះនេះនោះទេ។

ប៉ុន្តែព្រះបានឮពីការបារម្ភរបស់អ័ប្រាហាំ ហើយទ្រង់បានមានផែនការមួយ។ ព្រះបានប្រាប់អ័ប្រាហាំកុំឲ្យបារម្ភពីអ៊ីសម៉ាអែល ព្រោះថាវាមិនអីទេសម្រាប់អ៊ីសម៉ាអែលដើម្បីផ្លាស់ទៅទីឆ្ងាយនោះ។ ព្រះបានសន្យាថា នឹងការពារដល់អ៊ីសម៉ាអែល។ ដូច្នេះនៅពេលព្រឹកព្រលឹម អ័ប្រាហាំបានខ្ចប់អាហារ និងទឹកមួយចំនួនឲ្យទៅ អ៊ីសម៉ាអែល និងហាការ។ ពួកគេបានបន្តដំណើរចូលទៅក្នុងទីរហោស្ថាន។

នៅឯទីរហោស្ថានគឺពិតជាក្តៅ និងស្រេកទឹកខ្លាំងណាស់។ ហាការ និងអ៊ីសម៉ាអែលក៏ បានផឹកទឹកដែលអ័ប្រាហាំបានឲ្យពួកគេនោះ។ មិនយូរប៉ុន្មានទឹកក៏បានអស់ ហើយហាការ និងអ៊ីសម៉ាអែលក៏មានការស្រេកទឹកជាខ្លាំង។ ពួកគេមិនអាចស្វែងរកទឹកបាននោះទេ។ ពួកគេគឺពិតជាស្រេកទឹកណាស់ ហើយពួកគេគិតថាពួកគេនឹងត្រូវស្លាប់។ នៅគ្រប់ទីកន្លែងដែលហាការ និងអ៊ីសម៉ាអែលមើល អ្វីៗដែលពួកគេបានរកឃើញគឺជាវាលខ្សាច់ដ៏ក្តៅ ស្ងួត និងមានតែធូលីដីប៉ុណ្ណោះ។

អ៊ីសម៉ាអែលមានការស្រេកទឹកជាខ្លាំង ហើយគេក៏ចាប់ផ្តើមយំ។ ម្តាយគាត់បានដាក់គាត់នៅក្រោមគុម្ពោតមួយកន្លែងដែលមានម្លប់បន្តិចពីពន្លឺថ្ងៃដ៏ក្តៅ។ វាគឺពិតជាមានការឈឺចាប់ណាស់សម្រាប់ហាការក្នុងការដែលឃើញកូនប្រុសរបស់នាងយំ ហើយនាងមិនអាចជួយអ្វីដល់កូនបាននោះ។ ហាការក៏ចាប់ផ្តើមយំដែរ។ ប៉ុន្តែព្រះបានឮហាការ និងអ៊ីសម៉ាអែលយំ។ ព្រះបានចូលមកឯហាការ ហើយប្រាប់នាងថាកុំឲ្យខ្លាចឡើយ។ ព្រះអង្គបានប្រាប់នាងថាទ្រង់បានឮអ៊ីសម៉ាអែលយំ ហើយថាទ្រង់នឹងមើលថែគេ។

បន្ទាប់មកព្រះក៏បានបង្ហាញអណ្តូងទឹកមួយដល់ហាការ ដែលនាងមិនបានឃើញពីមុន។ ហាការ និងអ៊ីសម៉ាអែល ក៏ប្រញាប់ទៅកាន់អណ្តូងទឹកនោះហើយផឹកទឹកហើយផឹកទៀត។ ព្រះបានមើលថែ អ៊ីសម៉ាអែលដូចជាអ្វីដែលទ្រង់បានសន្យាជាមួយអ័ប្រាហាំ ទ្រង់នឹងបង្កើតជាតិសាសន៍មួយតាមរយៈអ៊ីសម៉ាអែល។

ព្រះស្រលាញ់យើងខ្លាំងណាស់ ហើយទ្រង់ក៏បានស្តាប់ពីអ្វីដែលយើងបាននិយាយផងដែរ។ ព្រះគឺតែងតែស្តាប់ការអធិស្ឋានរបស់យើងជានិច្ច មិនថាតាមរយៈការសរសើរតម្កើង ការយំ ការសើច ឬក៏ការថ្វាយបង្គំនោះទេ។ ព្រះគឺតែងតែស្តាប់ពួកយើង នៅពេលដែលយើងអធិស្ឋាន ឬក៏និយាយទៅកាន់ព្រះអង្គ!

## ៦. សំនួរពិភាក្សា

១. តើអ៊ីសម៉ាអែលគឺជានរណា? *(គាត់គឺជាកូនប្រុសរបស់អ័ប្រាហាំ)*

២. តើនរណាគឺជាម្តាយរបស់អ៊ីសម៉ាអែល? *(ហាការ)*

៣. តើមានរឿងអ្វីកើតឡើងនៅក្នុងសាច់រឿងនេះ?
*(សារ៉ា និងហាការគឺមិនចូលចិត្តគ្នានោះទេ។ សារ៉ាចង់ឲ្យហាការ និងអ៊ីសម៉ាអែលចេញឲ្យឆ្ងាយ)*

៤. ហេតុអ្វីបានជាព្រះមកជួយដល់ហាការ និងអ៊ីសម៉ាអែល? *(ព្រោះទ្រង់បានឮពួកគេយំ ហើយទ្រង់ក៏បានសន្យាជាមួយអ័ប្រាហាំថានឹងការពារដល់អ៊ីសម៉ាអែលផងដែរ)*

៥. តើអ្នកអាចធ្វើអ្វីបាននៅពេលជួបការលំបាក? *(អធិស្ឋានទៅកាន់ព្រះ)*

**៧. ល្បែងកំសាន្ត** **«ញុាំម្ហូរធ្វើមុខញញឹម»**




សម្ភារៈដែលត្រូវការ៖ អំបិលម្ទេស និងម្ហូរ តុ១ កៅអី២

១. ចែកកុមារជាពីរក្រុម

២. គ្រូត្រូវដាក់ម្ហូរ អំបិលម្ទេស ហើយដាក់វានៅលើតុ

៣. ជ្រើសរើសតំណាងក្រុមម្នាក់ពីក្រុមទាំងពីរ មកអង្គុយលើកៅអីទល់មុខគ្នា

៤. នៅពេលដែលគ្រូនិយាយ “១២៣” ពួកគេត្រូវញុាំម្ហូរណាមួយក៏បាន ដោយជ្រលក់ជាមួយអំបិលម្ទេស។ ហើយគេត្រូវតែញុាំវាដោយទឹកមុខញញឹម។ ប្រសិនបើកុមារណាម្នាក់ជ្រួញចិញ្ចើម ឬក៏ស្ដោះវាចេញនោះ គេនឹងចាញ់ល្បែងនេះ។

៥. បន្តលេងល្បែងនេះរហូតដល់កុមារបានលេងគ្រប់ៗគ្នា។ ក្រុមណាដែលមានពិន្ទុច្រើនជាងនោះក្រុមរបស់ ពួកគេនឹងឈ្នះល្បែងនេះ

៦. បន្ទាប់បីលេងល្បែងនេះចប់ សូមពន្យល់កុមារថា ជីវិតរស់នៅរបស់យើងគឺមិនតែងតែងាយ ស្រួលរហូតនោះទេ។ ប៉ុន្តែពួកយើងនៅតែអាចមានអំណរពីព្រោះព្រះតែងតែឮពីសេចក្តីអធិស្ឋានរបស់យើងជានិច្ច។

**៨. ខគម្ពីរចងចាំ**

**យ៉ូហាន ១៥៖៧** *“បើអ្នករាល់គ្នានៅជាប់នឹងខ្ញុំ ហើយពាក្យខ្ញុំនៅជាប់ក្នុងអ្នករាល់គ្នា នោះចូរសូមអ្វីតាមតែប្រាថ្នាចុះ សេចក្តីនោះនឹងបានសំរេចដល់អ្នករាល់គ្នាជាមិនខាន។”*

**៩. ហត្ថកម្ម** **«ព្រះសណ្ដាប់យើង ពេលយើងអធិស្ឋាន»**



សម្ភារៈដែលត្រូវការ៖ ព្រីនក្រដាសហត្ថកម្ម និងកូល័រ

១. ផាត់ពណ៌រូបអ៊ីសម៉ាអែលនិងហាការ

២. គូសរូបព្រះនៅចន្លោះអ៊ីសម៉ាអែលនិងហាការ ដែលបានឮការអធិស្ឋានរបស់ពួកគេ និងមកជួយដល់ពួកគេផងដែរ។

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន**

| |
|---|
| **ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**<br>ដោយព្រោះតែព្រះយេស៊ូវយើងអាចដឹងបានថា ព្រះគឺតែងតែឮពីពួកយើង។ ព្រះយេស៊ូវត្រូវបានបញ្ជូនមកយើងដើម្បីបង្ហាញពីព្រះចេស្តានៃព្រះ ដើម្បីបំពេញគ្រប់តម្រូវការរបស់យើង សូម្បីតែមុនពេល យើងសុំក៏ដោយ។ សូមគិតអំពីពេលវេលាមួយដែលវាពិបាកសម្រាប់អ្នក។ ក្នុងអំឡុងពេលនោះ តើអ្នកបានស្វែងរកជំនួយពីព្រះ ឬមានអារម្មណ៍ថាមានវត្តមានរបស់ទ្រង់ឬទេ? ឬវាពិបាកសម្រាប់អ្នកក្នុងការពឹងផ្អែកលើព្រះ? សូមអធិស្ឋានអំពីបញ្ហាដែលអ្នកកំពុងប្រឈមមុខនៅពេលនេះ។ ចូរសុំព្រះឲ្យបើកសម្តែងវិធីខ្លះដែលបង្ហាញថាទ្រង់ឮអ្នក ពីព្រោះព្រះទ្រង់តែងតែស្តាប់យើងពេលយើងអធិស្ឋានជានិច្ច។ |

# ព្រះសណ្តាប់យើង ពេលយើងអធិស្ឋាន



ការណែនាំ៖

១. ផាត់ពណ៌រូបអ៊ីសម៉ាអែល និងហាការ

២. គូសរូបព្រះនៅចន្លោះអ៊ីសម៉ាអែល និងហាការ ដែលបានឮការអធិស្ឋានរបស់ពួកគេ និងបានមកជួយដល់ពួកគេផងដែរ។